# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ...០៩...សរណន**

## សារាចរណែនាំ

## ស្តីពី

## ការពង្រឹងវិធានការការពារសន្តិសុខ និងសុវត្ថិភាព ជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិ

~~~~~~~~

កន្លងមកថ្មីៗនេះ រាជរដ្ឋាភិបាលបានសង្កេតឃើញថា នៅតំបន់ទេសចរណ៍មួយចំនួនក្នុងព្រះរាជាណាចក្រកម្ពុជា ពិសេសនៅរាជធានីភ្នំពេញ និងនៅទីក្រុងព្រះសីហនុ បានកើតឡើងនូវសកម្មភាពអសកម្មដែលបង្កឡើងដោយជនខិលខូចមួយចំនួនតូច តែងតែដើរលួច ឆក់ ប្លន់ទ្រព្យសម្បត្តិ ឬចាប់រំលោភ បង្កឱ្យមានរបួសស្នាមលើរូបរាងកាយរបស់អ្នកទេសចរជាតិ និងអន្តរជាតិ។ ទន្ទឹមនេះ ការលក់ដូរវត្ថុអនុស្សាវរីយ៍ អនាម័យម្ហូបអាហារតាមភោជនីយដ្ឋាននានា និងគ្រោះថ្នាក់ផ្សេងៗចំពោះភ្ញៀវទេសចរក៏នៅមានជួបបញ្ហាអសកម្មខ្លះៗនៅឡើយដែរ។

ដើម្បីបន្តពង្រឹងឱ្យបាននូវការជឿទុកចិត្ត និងភាពកក់ក្តៅរបស់ភ្ញៀវទេសចរជាតិ និងអន្តរជាតិចំពោះសន្តិសុខ និងសុវត្ថិភាពក្នុងដំណើរទស្សនកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចតទៅ ÷

១-ក្រសួងមហាផ្ទៃ និងអគ្គស្នងការដ្ឋាននគរបាលជាតិ សហការជាមួយអាជ្ញាធរដែនដីខេត្ត-ក្រុង ត្រូវចាត់វិធានការចាំបាច់បន្ទាន់នានា ដើម្បីពង្រឹងកិច្ចការពារសន្តិសុខ និងសុវត្ថិភាពជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ជាពិសេសតំបន់ទេសចរណ៍សំខាន់ៗ ជាអាទិ៍ នៅរាជធានីភ្នំពេញ ខេត្តសៀមរាប ក្រុងព្រះសីហនុ ក្រុងកែប តំបន់ភូមិភាគឦសានជាដើម និងតំបន់គោលដៅទេសចរណ៍ដាច់ស្រយាលនានា សំដៅបញ្ជៀសនូវបាតុភាពលួច ឆក់ ប្លន់ ពីសំណាក់ជនខិលខូចមួយចំនួនតូច និងបាតុភាព អសកម្មខ្លះៗចំពោះភ្ញៀវទេសចរជាតិ និងអន្តរជាតិ ដូចរយៈពេលកន្លងមក។
~~~~~~~~

២-ក្រសួងទេសចរណ៍ និងក្រសួងមហាផ្ទៃ ត្រូវធ្វើការណែនាំជាបន្ទាន់ដល់ក្រុមហ៊ុន សណ្ឋាគារ ម្ចាស់ផ្ទះសំណាក់ទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ឱ្យពង្រឹងការងារចុះបញ្ជីឈ្មោះ អត្តសញ្ញាណភ្ញៀវជាតិ និងអន្តរជាតិ ដែលចេញ ចូល ស្នាក់នៅតាមសណ្ឋាគារ និងផ្ទះសំណាក់ឱ្យបានម៉ត់ចត់បំផុត ព្រមទាំងត្រូវឱ្យធ្វើការខិតខំបំពាក់ឧបករណ៍កាមេរ៉ាត្រួតពិនិត្យសន្តិសុខថែមទៀតផង ។

គ្រប់សណ្ឋាគារ និងផ្ទះសំណាក់ ត្រូវចាត់ចែងរៀបចំឱ្យមានកងរក្សាសន្តិសុខយាមប្រចាំការជាអចិន្ត្រៃយ៍ ដើម្បីត្រួតពិនិត្យតាមដានលើរាល់សកម្មភាពរបស់ជនខិលខូច ដែលមានបំណងអាក្រក់ធ្វើឱ្យប៉ះពាល់ដល់រូបរាងកាយ និងទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ភ្ញៀវទេសចរ ។

៣-ក្រសួងទេសចរណ៍ ត្រូវសហការជាមួយធនាគារជាតិនៃកម្ពុជា និងត្រូវមានវិធានការត្រួតពិនិត្យឱ្យបានម៉ត់ចត់ដល់គុណភាពវត្ថុមានតម្លៃទាំងឡាយមុននឹងដាក់លក់ជូនភ្ញៀវ ។ ក្នុងករណីមានភស្តុតាងច្បាស់លាស់ ម្ចាស់ហាងលក់ដូរវត្ថុអនុស្សាវរីយ៍ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ត្រូវមានវិធានការពង្រឹងការគ្រប់គ្រង រាល់មធ្យោបាយដឹកជញ្ជូនភ្ញៀវទេសចរឱ្យបានម៉ត់ចត់ រាប់ទាំងមធ្យោបាយដឹកជញ្ជូនសាមញ្ញ និងបូរាណ ម៉ូតូឌុប ក្នុងការដឹកជញ្ជូនភ្ញៀវទេសចរ ។

ត្រូវបង្កើនការដឹកនាំ និងគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរដែលជាតួអង្គយ៉ាងសំខាន់ ក្នុងការរួមចំណែកការពារកិត្យានុភាព និងប្រវត្តិសាស្ត្ររបស់ជាតិ និងកិច្ចការពារសន្តិសុខ និងសុវត្ថិភាពជូនភ្ញៀវទេសចរផងដែរ ។

៤-ក្រសួងសុខាភិបាល ត្រូវត្រៀមលក្ខណៈរថយន្តពេទ្យចល័ត ដើម្បីជួយសង្គ្រោះភ្ញៀវទេសចរដែលមានគ្រោះថ្នាក់ជាបន្ទាន់ ដោយប្រចាំការជាអចិន្ត្រៃយ៍តាមគោលដៅទេសចរណ៍នានាឱ្យបានច្រើនកន្លែងតាមដែលអាចធ្វើទៅបាន ។

ត្រូវមានវិធានការត្រួតពិនិត្យអនាម័យម្ហូបអាហារជាទូទៅ ពិសេសនៅតាមភោជនីយដ្ឋានដែលមានប្រជាប្រិយចំពោះភ្ញៀវទេសចរ ។

៥-អាជ្ញាធរជាតិទេសចរណ៍កម្ពុជា ត្រូវធ្វើសន្និបាតបូកសរុប វាយតម្លៃ និងលើកទិសដៅផែនការសំរាប់កិច្ចការពារសន្តិសុខ និងសុវត្ថិភាពជូនភ្ញៀវទេសចរឱ្យបានល្អ ហើយបន្ទាប់មកអាជ្ញាធរខេត្ត ក្រុង ត្រូវសហការ

ជាមួយសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីធ្វើការប្រជុំបូកសរុប វាយតម្លៃ និងលើកទិសដៅផែនការការពារសន្តិសុខ និងសុវត្ថិភាពជូនភ្ញៀវឱ្យបានល្អនៅតាមគោលដៅទេសចរណ៍នានាក្នុងមូលដ្ឋានខេត្ត ក្រុងសាមី។

៦-ក្រសួងការពារជាតិ អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថលើផ្ទៃប្រទេស ត្រូវសហការជាមួយក្រសួងមហាផ្ទៃ និងអគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីលើកវិធានការរួមចំណែកក្នុងកិច្ចការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ឱ្យបានកាន់តែល្អប្រសើរថែមទៀត ដើម្បីបង្កើនជំនឿទុកចិត្តរបស់វិនិយោគិន អង្គការជាតិ និងអន្តរជាតិ ស្ថានទូត និងស្ថានតំណាងនានា ប្រចាំព្រះរាជាណាចក្រកម្ពុជា ជាពិសេសភ្ញៀវទេសចរជាតិ និងអន្តរជាតិ។

ទទួលបានសារាចរណែនាំនេះ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងទេសចរណ៍ ក្រសួងព័ត៌មាន ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីខេត្ត ក្រុង ត្រូវធ្វើការផ្សព្វផ្សាយ និងចាត់ចែងអនុវត្តឱ្យទទួលបានលទ្ធផលជាវិជ្ជមាន។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចម្លងជូន:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-គ្រប់ក្រសួង ស្ថាប័ន
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-គ្រប់សាលាខេត្ត ក្រុង
-ឯកសារ-កាលប្បវត្តិ